ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលជំនួបរវាងឯកឧត្តម កែវ រ៉េមី ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាមួយឯកឧត្តម Anatoly Borovik ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ ឯកឧត្តម **កែវ រ៉េមី** ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Anatoly Borovik ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាការងារ នៅសាលប្រជុំគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ កិច្ចប្រជុំនេះបានផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យសិទ្ធិមនុស្សរវាងប្រទេសទាំងពីរ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រីបានសម្តែងការស្វាគមន៍ចំពោះឯកឧត្តម Anatoly Borovik និងសហការី និងបានគូសបញ្ជាក់ពីការយកចិត្តទុកដាក់របស់ប្រទេសកម្ពុជា ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ព្រមទាំងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យសិទ្ធិមនុស្សតាមរយៈការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗចំនួន ៨ ក្នុងចំណោម ៩ និងការស្វាគមន៍វត្តមានរបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR) ជាដើម។

ក្នុងកិច្ចជំនួបនេះ ឯកឧត្តម Anatoly Borovik បានថ្លែងអំណរគុណឯកឧត្តមទេសរដ្ឋមន្ត្រី ដែលបានចំណាយពេលដ៏មមាញឹកអនុញ្ញាតឱ្យឯកឧត្តម និងសហការីបានចូលជួបពិភាក្សាការងារ និងបានកោតសរសើរប្រទេសកម្ពុជា ក្នុងការអនុញ្ញាតឱ្យមានវត្តមានរបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និង OHCHR នៅកម្ពុជា ព្រមទាំងមានវត្តមានអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិដ៏ច្រើនសន្ធឹកសន្ធាប់។ កត្តាទាំងនេះ គឺជាសក្ខីកម្មដែលបានឆ្លុះបញ្ចាំងពីការបើកចំហរបស់ប្រទេសកម្ពុជាលើវិស័យសិទ្ធិមនុស្ស។ ទន្ទឹមនឹងនេះ ឯកឧត្តមបានលើកឡើងពីគម្រោងទស្សនកិច្ចរបស់លោកជំទាវបណ្ឌិត Tatiana Moskalkova ឧត្តមស្នងការសិទ្ធិមនុស្សរបស់សហព័ន្ធរុស្ស៊ី មកប្រទេសកម្ពុជា និងសង្ឃឹមថាកិច្ចសហប្រតិបត្តិការរវាងរុស្ស៊ីនិងកម្ពុជាលើវិស័យសិទ្ធិមនុស្សនឹងកាន់តែប្រសើរឡើង ដោយឈរលើគោលការណ៍ឯករាជ្យភាព អធិបតេយ្យភាព និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសដទៃ។

*អគារលេខ៣ ផ្លូវ VI.13 ភូមិទួលសំពៅ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ*
*Building #3, Street VI.13, Toul Kok Village, Sangkat Toul Sangke, Khan Russey Keo, Phnom Penh* *Tel: (855) 23 882 065*

បន្ថែមពីនេះ ឯកឧត្តមអគ្គរដ្ឋទូត ក៏បានលើកឡើងពីការយកចិត្តទុកដាក់លើការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនៅសហព័ន្ធរុស្ស៊ី ជាពិសេស ចំពោះសិទ្ធិកុមារ។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានធ្វើការវាយតម្លៃខ្ពស់ចំពោះការគូសបញ្ជាក់របស់ឯកឧត្តមអគ្គរដ្ឋទូត លើគោលការណ៍ដែលបានលើកឡើង ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងរុស្ស៊ីនិងកម្ពុជាលើវិស័យសិទ្ធិមនុស្ស និងការលើកកម្ពស់និងការការពារសិទ្ធិកុមាររបស់សហព័ន្ធរុស្ស៊ី។

កិច្ចជំនួបនេះ បានបញ្ចប់ទៅក្រោមបរិយាកាសស្និទ្ធស្នាល យោគយល់ និងសម្រេចបានលទ្ធផលគួរជាទីពេញចិត្ត៕

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤